# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ប្រុញ ទុំ ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ «និរសាឃុំទឹកថ្លា ស្រុកសិរីសោភ័ណ្ឌ»
## ស្រុកកំណើតនៅភូមិទួលត្បែង ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ
## សព្វថ្ងៃរស់នៅភូមិចក្រី ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង
## ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៤៦:១៩
## ២៥ ទំព័រ

ដានីៈ បាទ! ចឹងអ៊ីងបងអ៊ី! ខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញឈ្មោះអីដែរ?

ទុំៈ ខ្ញុំ ឈ្មោះ ប្រុញ ទុំ!

ដានីៈ ឈ្មោះ ប្រុញ ទុំ?

ទុំៈ ចា៎ស!

ដានីៈ ប្រុញ?

ទុំៈ ចា៎ស!

ដានីៈ ប្រុញ ទុំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ទុំៈ ៥៨ ហើយ ។

ដានីៈ ៥៨ហេ៎?

ទុំៈ ចា៎ស!

ដានីៈ នៅក្មេងដែរ អ៊ំ! ស្រុកកំណើតកើតជានៅឯណាដែរទៅ?

ទុំៈ ខ្ញុំនៅព្រៃស្បាតនៅ ទួលត្បែង ។

ដានីៈ ភូមិទួលត្បែង?

ទុំៈ ចា៎ស!

ដានីៈ ភូមិទួលត្បែង ឃុំជាងទង ស្រុកត្រាំកក់ ។ ត្រាំកក់ កាលហ្នឹងគេហៅស្រុក១០៥ហេ៎?

ទុំៈ ចា៎ស! កាលហ្នឹងគេហៅ១០៥ចឹងហើយ, ខ្ញុំមិនសូវចាំដែរយូរហើយ ។

ដានីៈ ត្រាំកក់ ១០៥, ខេត្តតាកែវ កាលហ្នឹងគេហៅតំបន់អីទៅ?

ខ្ញុំៈ អត់ចាំទេយូរហើយភ្លេច ។

ដានីៈ យូរហើយ បាទ! ហើយសព្វថ្ងៃអ៊ំនៅភូមិ ឃុំ ស្រុកអីដែរសព្វថ្ងៃនេះ?

ខ្ញុំៈ សព្វថ្ងៃនេះខ្ញុំនៅ!

ដានីៈ ភូមិអីដែរ?

ខ្ញុំៈ ស្រុកភ្នំព្រឹក ភូមិចក្រីដែរ អាដេងនេះ? ឃុំបារាំធ្លាក់?

ដានីៈ ឃុំបារាំងធ្លាក់, ឃុំចក្រីហេ៎?

អ្នកជិតខាងៈ ភូមិចក្រី ឃុំបារាំងធ្លាក់ ។

ដានីៈ ភូមិចក្រី ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹកនៅនេះ?

ខ្ញុំៈ ចា៎ស!

ដានីៈ ខេត្តបាត់ដំបង មិនមែនបន្ទាយមានជ័យ ។

ខ្ញុំៈ ចា៎ស!

ដានីៈ គ្រួសាររបស់អ៊ំឈ្មោះអីដែរ?

ខ្ញុំៈ គាត់ឈ្មោះ រស់ ផាត ។

ដានីៈ ឈ្មោះរស់ ផាត! គាត់ឈ្មោះរស់ ផាតហ្នឹងចឹងរហូតមក ឬក៏មានប្រែឈ្មោះអីដែរ?

ខ្ញុំៈ ខ្ញុំមិនដឹងម៉េច ឈ្មោះដើមគាត់ដឹងឈ្មោះអី! នេះប្អូនគាត់ សួរប្អូនគាត់អត់ស្គាល់ដែរកាលហ្នឹង ។

ដានីៈ ចឹង?

ខ្ញុំៈ ចា៎ស!

ប្អូនរស់ ផាតៈ ពីមុនហៅ បងអុកៗ!

ខ្ញុំៈ ចែ! ពីមុនមកគេហៅអីគេ?

ប្អូនរស់ ផាតៈ ចា៎ស! ពីដើមមកហៅ អុកៗ ។

អ្នកជិតខាងៈ ឈ្មោះ អុក ។

ដានីៈ ឈ្មោះ ពីកំណើត នៅផ្ទះអីគេហៅអុក ហេ៎?

ប្អូនរស់ ផាតៈ ឈ្មោះ ពីកំណើត ឈ្មោះ ផាតតែម្តង ប៉ុននៅស្រុកគេហៅអុកៗ ។

ដានីៈ អុក?

ខ្ញុំៈ ចា៎ស!

ដានីៈ ហៅអុកៗ ដល់ពេលជំនាន់ក្រោយចូលបដិវត្តន៍ឈ្មោះគាត់ផាតដដែរ?

ប្អូនរស់ ផាតៈ គាត់នៅរៀនក៏ឈ្មោះ ផាតប៉ុនដល់នៅស្រុកអ្នកស្រុកហៅ អុកៗ ។

ដានីៈ   អូ!

ប្អូនរស់ ដាតៈ  នៅរៀនក៏ឈ្មោះ ដាត ធ្វើការអីក៏ឈ្មោះដែរ ។

ដានីៈ   ឈ្មោះ អុក! គាត់ខូចពីអង្កាល?

ទុំៈ     ខែ៩  ថ្ងៃទី១២ ។

ដានីៈ   ខូចពីកាលខែ៩  ថ្ងៃទី១២នេះ?

ទុំៈ     ចា៎ស!

ដានីៈ   ពីរខែមុននេះ ឥឡូវថ្ងៃ១២  ខែ៨, ៣ខែហើយហ៎?

ទុំៈ     ចា៎ស!

ដានីៈ   ខែ៩  ថ្ងៃទី១២, គាត់ឈឺអីដែរ  កាលគាត់ខូចហ្នឹង?

ទុំៈ     គាត់ឈឺ!  មិនដឹងថាមុខឈឺអីផង  ដូចគាត់នៅរវើកដែរ  យប់ឡើងដូចគាត់ហត់  ពេលថ្ងៃចឹង គាត់ហត់ប៉ុននៅអង្គុយលេងធម្មតា ដល់យប់ម៉ោង១  បានគាត់ស្លាប់ ។

ដានីៈ   យប់ម៉ោង១?

ទុំៈ     ចា៎ស!

ដានីៈ   គាត់ស្លាប់នៅហ្នឹងតែម្តង?

ទុំៈ     ស្លាប់ទៅកើតនោះ ។

ដានីៈ   ហើយគាត់អាយុប៉ុន្មានដែរ?

ទុំៈ     គាត់អាយុ៦៤ ចែ?

ប្អូនរស់ ដាតៈ  ៦៤!

ដានីៈ   អាយុ៦៤ឆ្នាំ ។  ហើយចុះអ៊ីកូនមានកូនអីប៉ុន្មាននាក់ដែរ?

ទុំៈ     ខ្ញុំមាន៧នាក់ ។

ដានីៈ   កូន៧នាក់!  ស្រីប៉ុន្មាន  ប្រុសប៉ុន្មាន?

ទុំៈ     ស្រី៣  ប្រុស៤ ។

ដានីៈ   ប្រុស៤!  ហើយអ៊ីប្រុស  គាត់មានប្រពន្ធមុន  ចុះប្រពន្ធមុនគាត់ឈ្មោះអីដែរទៅ?

ទុំៈ     ខ្ញុំស្គាល់តែឈ្មោះ  តែត្រកូលខ្ញុំអត់ស្គាល់ទេ ។

ដានីៈ   បាទៗ!

ទុំៈ     ឈ្មោះ ផល ។

ដានីៈ   ឈ្មោះ ផល!  ឈ្មោះ ផល  ស្រុកកំណើតគាត់នៅឯណាដែរ?

ទុំៈ ស្រុកកំណើតនៅភូមិ!

អ្នកជិតខាងៈ កើតនៅភូមិរំចូត ។

ទុំៈ អត់ទេប្រពន្ធណា?

អ្នកជិតខាងៈ ស្រុកកំណើតប្រពន្ធនៅឯព្រៃនេះ, កាលហ្នឹងឯ ១០៨ នៅ៨មុំ ។

ទុំៈ ខ្ញុំអត់ស្គាល់ដែរ ។

ដានីៈ ១០៨ នៅតាកែវដែរ?

ប្អូនរស់ ដាតៈ ចា៎ស! នៅតាកែវដែរ ។

ដានីៈ ខាងកោះអណ្ដែត ឬនៅខាងគីរីវង្ស?

ទុំៈ ខាងកោះអណ្ដែត!

ប្អូនរស់ ដាតៈ មិនមែនគីរីវង្សទេ! ខាងកោះអណ្ដែត ។

ដានីៈ អង្គរជ័យខាងកោះអណ្ដែត?

ប្អូនរស់ ដាតៈ អត់ទេ! អង្គរជ័យនៅខ្ញុំនែក! ខ្ញុំនៅឯអង្គរជ័យតែគាត់នៅខាងបៀតបារាយណ៍ ។ ជិតបារាយណ៍ជំនាយើងពីយើងភ្នំត្រែងយើងនេះ ។

ដានីៈ ហ្វូ! ចឹងអ៊ឹដាត គាត់នៅស្រុកកោះអណ្ដែត?

អ្នកជិតខាងៈ អ៊ឹ ដាតស្រុកកណើតគាត់នៅឃុំ សំឡាញ!

ដានីៈ ឃុំ សំឡាញ?

អ្នកជិតខាងៈ ចា៎ស!

ដានីៈ ភូមិអីគេហ្នឹង?

ប្អូនរស់ ដាតៈ ភូមិអង្គចូត ឃុំសំឡាញ ស្រុកអង្គជ័យ ខេត្តកំពត ។

ដានីៈ ហ្វូ! ចឹង គាត់នៅខាង ភូមិអង្គចូត ឃុំ?

ប្អូនរស់ ដាតៈ ឃុំសំឡាញ ស្រុកអង្គជ័យខេត្តកំពត ។

ដានីៈ ហ្វូ! ត្រូវជាបងរបស់អ៊ឹបង្កើត?

ប្អូនរស់ ដាតៈ គាត់ត្រូវជាបងបង្កើត ។

ទុំៈ នេះ! គាត់នៅភូមិអង្គខ្នុរ ឬក៏កកោះទេខ្ញុំភ្លេចហើយ!

ប្អូនរស់ ដាតៈ ខ្ញុំមិនបាននៅមួយជងនៅឯស្រុក ។

ដានីៈ បាទៗ! ហើយចុះកាលប្រពន្ធមុនគាត់មានកូនប៉ុន្មាននាក់ដែរ?

ទុំៈ កូនតែមួយហ្នឹងឯង ។

ដានី៖ កូនតែមួយហ្នឹង ។

អ្នកជិតខាង៖ ខូចទាំងម៉ែ ខូចទាំងកូន ។

ដានី៖ ប្រពន្ធស្លាប់ដោយសារមូលហេតុអីទៅ?

ទុំ៖ យើងរត់៧៩នោះ មានអីហូប! គ្មាននោះ ។

ដានី៖ ហ៎ូ! បាទៗ! ហើយដល់ពេលមកបានអ៊ីបានកូន៧នាក់ទៀត ។

ទុំ៖ ចា៎ស!

ដានី៖ បាទ! ការជាមួយគាត់ឆ្នាំណា?

ទុំ៖ ការ៧៩ ជិតដាច់ហើយដឹង! កាលយើងរត់នោះ ។

ដានី៖ ឆ្នាំ១៩៧៩ ពេលរត់ហ៎?

ទុំ៖ ចា៎ស! រត់ចូលជំរំ ។

អ្នកជិតខាង៖ គាត់និសោ! ខ្ញុំនៅជាមួយគាត់ហ្នឹង ។

ទុំ៖ នៅជាមួយគាត់ ទើបតែមកហ្នឹងឯង ហេតុដែលខ្ញុំមិនស្គាល់ប្រវត្តិគាត់ព្រោះទើបនៅដែរមកនេះ ហ្នឹង ។

ដានី៖ ចុះនៅខាងស្រុកកំណើត ឪពុកម្តាយអ៊ីធ្វើអីដែរ?

ទុំ៖ ចា៎ស! ខ្ញុំហេ៎?

ដានី៖ បាទ!

ទុំ៖ ឪពុកម្តាយខ្ញុំឈ្មោះ ចាប អ៊ុន ។

ដានី៖ គាត់នៅ ឬក៏ខូចអស់ហើយ?

ទុំ៖ គាត់ស្លាប់អស់ហើយ ។

ដានី៖ ម្តាយឈ្មោះអី ចឹង?

ទុំ៖ ចាប អ៊ុនហ្នឹងម៉ែ!

ដានី៖ ម្តាយឈ្មោះ ចាប អ៊ុន?

ទុំ៖ ចា៎ស!

ដានី៖ ឪពុក?

ទុំ៖ ឪពុកឈ្មោះ ប្រុញ ទី ។

ដានី៖ គាត់ខូចអស់ហើយ ។ ហើយ! មានបងប្អូនប៉ុន្មាននាក់ដែរ?

ខ្ញុំ៖ មានបងប្អូន៦នាក់ ឥឡូវសល់តែ៣នាក់ទេ។ បើបាត់អស់ហើយ ថាមួយនោះថាចេញពីជំរំទៅ ថាទៅនៅប្រទេសគេ ដល់ឥឡូវទៅរកអត់ឃើញ ដឹងនៅទីណា។

ដានី៖ ៦នាក់! ឥឡូវនៅសល់ប៉ុន្មាននាក់?

ខ្ញុំ៖ សល់៣! សល់តែ៣។

ដានី៖ សល់តែ៣ទេ!

ខ្ញុំ៖ ចាស៎!

ដានី៖ ៦នាក់ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខ្ញុំ៖ បានស្រី៤ ប្រុស២។ ស្លាប់អស់២ហើយ ប្រុសៗនោះ។

ដានី៖ អស់២ហើយចឹងនៅសល់៤។

ខ្ញុំ៖ នៅសល់៤ បាត់មួយ។

ដានី៖ បាត់មួយ! បាត់ស្រីហើយ ឬក៏ប្រុស?

ខ្ញុំ៖ បាត់ស្រី!

ដានី៖ បាត់ស្រី! ឮដំណឹងថាទៅស្រុកគេ?

ខ្ញុំ៖ ចាស៎!

ដានី៖ ធ្លាប់ជួបគ្នានៅជំរំដែរ?

ខ្ញុំ៖ គេនៅជំរំម៉ៃរូត។

ដានី៖ ប៉ុន្តែ ធ្លាប់បានជួបគ្នាដែរទេ?

ខ្ញុំ៖ អត់បានជួបទេ តែគ្រាន់គេអ្នកស្គាល់ គេស្គាល់ថានៅហ្នឹង ហើយគេទៅដូចថាកុមារកំព្រាហ្នុ៎! ហើយគេថាទៅប្រទេសក្រៅបាត់ហើយ គេប្រាប់ហើយខ្ញុំក៏អត់ដឹង អត់ដែលបានជួប គ្រាន់តែគេប្រាប់ប៉ុណ្ណឹង។

ដានី៖ បាទ! ហើយកាលពីក្មេងៗ អ៊ំបានរៀនសូត្រអីដល់ណាដែរ?

ខ្ញុំ៖ ខ្ញុំមិនបានរៀនហ្នឹងគេផង។

ដានី៖ អត់?

ខ្ញុំ៖ អត់!

ដានី៖ ចឹង! កាលហ្នឹងហេតុអីបានអត់បានរៀនសូត្រចឹង អត់ចេះអក្សរទេអីចឹង?

ខ្ញុំ៖ គ្មានចេះ។

ដានី៖ ឥឡូវមានចេះអាន ចេះសរសេរទេ?

ខ្ញុំៈ អត់(សើច)!

ដានីៈ អត់ទេ?

ខ្ញុំៈ អត់! ល្ងង់ណា ក្រុមគ្រួសារខ្ញុំល្ងង់ណាស់ ។

ដានីៈ ហើយចុះកាលពីជំនាន់រដ្ឋប្រហារទម្លាក់សម្ដេចឪអីនៅចាំទេ? នៅចាំរឿងរ៉ាវទេ?

ខ្ញុំៈ មិនបានចាំទេ! វាយូរហើយខ្ញុំនៅតូចដែរ ។

ដានីៈ ចឹងហ៎?

ខ្ញុំៈ ចា៎ស!

ដានីៈ កាលហ្នឹងធ្វើអីទៅ?

ខ្ញុំៈ ខ្ញុំមានស្អី នៅជាមួយម៉ែ ។

ដានីៈ កាលរដ្ឋប្រហារហ៎?

ខ្ញុំៈ ចា៎ស! នៅជាមួយម៉ែ ។

ដានីៈ នៅជាមួយម៉ែ?

ខ្ញុំៈ ចា៎ស!

ដានីៈ នៅដល់ពេលណាទៅបានហ៎?

ខ្ញុំៈ នៅទើបតែខ្ញុំចេញពីផ្ទះអាដែងគេហៅ គេប្រមូលទៅកងចល័តទេ ដល់មកបាត់ដំបងនេះគេហៅទៅក៏មកតាមគេមក ។

ដានីៈ ចឹង! កាលពីឆ្នាំ ៧០ នៅជាមួយឪពុកម្ដាយទេ?

ខ្ញុំៈ ចា៎ស! នៅជាមួយម៉ែឪ ។

ដានីៈ នៅជាមួយឪពុកម្ដាយធ្វើអីទៅកាលហ្នឹង?

ខ្ញុំៈ ខ្ញុំមិនធ្វើអីផងកាលហ្នឹង នៅតូចៗនៅមើលគោ មើលក្របីនៅតាមផ្ទះណា ។

ដានីៈ មើលគោ មើលក្របី?

ខ្ញុំៈ ចា៎ស!

ដានីៈ ហើយដល់ពេលបែកឆ្នាំ៧៥ ពេលដែលយើងបាយរួមណា៎ ពេលហ្នឹងអ៊ំនៅផ្ទះដដែរទេឬ?

ខ្ញុំៈ បាយរួម ខ្ញុំនៅផ្ទះ, អត់បានចេញផង ។

ដានីៈ ពេលបាយរួមនៅផ្ទះ នៅធ្វើអីដែលកាលហ្នឹង?

ខ្ញុំៈ នៅជាមួយម៉ែមានធ្វើអី មើលគោមើលអីជាមួយគេតាមសហករណ៍ គេឲ្យទៅមើលគោ ទៅមើលគោ ហ្នឹងគេទៅ រួចគោហើយមកនៅម៉ែវិញមក អត់បានដើរទៅណាហ្នឹងគេវិញផង ។

ដានី: កាលជិនទាន់ហ្នឹងនៅជាមួយឪពុកម្ដាយដែរហ្នឹង?

ខ្ញុំ: នៅៗ ។

ដានី: នៅតាមសហករណ៍ នៅជាមួយឪពុកម្ដាយ ។

ខ្ញុំ: ខ្ញុំទើបតែមកកាលពី ៧៧, ៧៨ហ្នឹងបានគេហៅ មក ហ៎ូ! មកនៅជាមួយគាត់ហ្នឹង ហើយក៏អត់ដែលស្គាល់គ្នាដែរហ្នឹង អត់ដែលស្គាល់គ្នាទេ (សើច) ។

ដានី: ហើយកាលនៅស្រុកហ្នឹង នៅគ្រាលគោគ្រាលអីទេ?

ខ្ញុំ: ចា៎ស!

ដានី: អត់ទាន់នៅក្នុងកងចល័ត កងកុមារអីទេ ។

ខ្ញុំ: នៅ! ព្រោះអត់ទាន់ មិនមែនចេញទេ ដូចខ្ញុំថាអីចឹងទើបតែចញមក គេហៅមកៗបាត់ដំបង ហ្នឹង មកជាមួយគេមក ។

ដានី: ឆ្នាំណាដែរ គេហៅមកបាត់ដំបង?

ខ្ញុំ: ឆ្នាំ៧៨ហ្នឹង ។

ដានី: ឆ្នាំ៧៨ ខែណាដែរ?

ខ្ញុំ: អត់ចាំខែទេ ។

ដានី: ខែដែលឆ្នាំ៧៨ហ្នឹង ដូចថាខែភ្លៀង ខែប្រាំង ឬក៏ខែយ៉ាងម៉េចពេលមកហ្នឹង ។

ខ្ញុំ: ឆ្នាំ៧៨ កាលពីឡើងមកនេះ ខែប៉ុន្មានចែ?

ប្អូនរស់ ដាគះ ឡើងមកនេះហ្នឹង ខ្ញុំម៉េចដឹង!

ខ្ញុំ: ៧៨ ហើយពេលដែលគាត់ឡើងមក ហៅខ្ញុំមកដែរ អត់ដឹងទេកន្លែងហ្នឹងនោះ អត់ដឹងខែប៉ុន្មាន អត់ចាំទេ ។

ដានី: បាទ! ចឹងអឺកាលពេលយើងមកបាត់ដំបង យើងយ៉ាងម៉េចគេប្រាប់ថាម៉េចខ្លះ ហើយអ៊ីយ៉ាង ម៉េចបានចេញពីផ្ទះមក មកពីតាកែវរហូតមកដល់?

ខ្ញុំ: គេថាតាមកស្រុកនេះ ហើយហៅទៅលេងបាត់ដំបងទេ ។ នៅហ្នឹងទៅ គេទៅហ្នឹងសប្បាយតា៎ គេអត់មានធ្វើអីទេ ហើយគេហៅមកក៏មកតាមគេមក ។

ដានី: ពីណាហៅ?

ខ្ញុំ: អ្នកអើយ! បងប្អូនខ្ញុំហ្នឹងណា គេមកហ្នឹងក៏មកជាមួយគេមក ឥឡូវបងខ្ញុំគេទៅស្រុកវិញទៅ ខ្ញុំក៏នៅនេះរហូតតែម្ដងទៅ ។

ដានី: បងស្រីណាដែលមកហៅទៅ?

ទុំៈ ឈ្មោះ សន ។

ដានីៈ ឈ្មោះ សន បងបង្កើត?

ទុំៈ បងជីដូនមួយ គេហៅមកជាមួយគេ ។

ដានីៈ គេហៅមក ហៅពីផ្ទះមក?

ទុំៈ ចា៎ស!

ដានីៈ កាលហ្នឹង ឪពុកម្ដាយឲ្យមកដែរ?

ទុំៈ ចុះបើគេហៅមក ចុះអាងតែគេបងប្អូនក៏ គេហៅថាមកក៏មក ដល់តែមកអត់បានទៅវិញ ។

ដានីៈ កាលហ្នឹងមកប៉ុន្មាននាក់ មកពីភូមិ?

ទុំៈ មកពីភូមិ មកតែម្នាក់ឯង ។

ដានីៈ មកម្នាក់ឯង មកជាមួយគាត់?

ទុំៈ ចា៎ស! ហើយអាងតែបង ។

ដានីៈ កាលហ្នឹងគេហៅថាមកលេងបាត់ដំបងចឹង?

ទុំៈ ចា៎ស! គេថាមកទៅលេងស្រុកបាត់ដំបងទេ ហើយមិនដឹងបាត់ដំបងហ្នឹងនៅឯណាអត់ស្គាល់ ដល់គេហៅមក មកហ្នឹងគេទៅ គេមកទៅ ។

ដានីៈ ហើយកាលហ្នឹង មកពីស្រុកហ្នឹង មកតែម្នាក់ឯងទេ?

ទុំៈ តែម្នាក់ឯង ។

ដានីៈ មកជាមួយគាត់ហ្នឹងមក?

ទុំៈ ចា៎ស! មកហ្នឹង ។

ដានីៈ កាលហ្នឹង គាត់មកធ្វើអី?

ទុំៈ មកហ្នឹងចេញមក មករកជួបគាត់ គាត់ទៅនៅខាងនោះខ្ញុំមកនៅជាមួយគាត់នេះ ។

ដានីៈ ប៉ុន្តែបងស្រីរបស់អ៊ីឈ្មោះ សន ហ្នឹងគាត់ធ្វើអីទៅ?

ទុំៈ មិនដឹងគាត់ធ្វើអី បើគាត់មកគាត់ចេញពីខ្ញុំ ខ្ញុំមកនៅជាមួយគាត់នេះ គាត់ទៅខាងអើយអន្លង់វិលហ្នឹងណា ។

ដានីៈ គាត់ទៅខាងអន្លង់វិលវិញ?

ទុំៈ ចា៎ស! គាត់ទៅខាងអន្លង់វិល ហើយខ្ញុំក៏ទៅនៅជាមយយគាត់វិញមក ។

ដានីៈ ដល់ពេលចឹង ពេលដែលមកពីស្រុកមកជាមួយបងស្រីហ្នឹង មកជិះអីមក ជិះអីមកឲ្យត្រង់មក បាត់ដំបងមក ឬក៏ចូលនៅឯណាដែរ ។

ទុំៈ ជិះរទេះភ្លើង! ជិះរទេះភ្លើងមក មកឈប់នៅបាត់ដំបង ។

ដានីៈ ជិះរទេះភ្លើងមកពីណាមក?

ទុំៈ ជិះយើងពីតាកែវអើយ មកអើយ ក៏រទេះភ្លើង រទេះភ្លើងអើយ!

ដានីៈ ក៏នៅតាកែវមក?

ទុំៈ ចា៎ស!

ដានីៈ ចឹងយើងមកពី

ទុំៈ ក៏ត្រង់ណាទេណា៎!

ដានីៈ អត់ចេញពីស្រុកមកសម្រាកអីនៅតាកែវ១យប់ហើយ គេអត់មកពីផ្ទះទេ មកឡើងរទេះភ្លើងទៅបណ្តោយ ។

ទុំៈ អាហ្នឹង ដូចថាយើងមកហ្នឹង ព្រលឹមឡើងបានយើងបានចេញ ។

ដានីៈ បាទ! មក មកសម្រាកនៅឯណា?

ទុំៈ នៅសិរី្ធ ។

ដានីៈ កាលហ្នឹង គេមានមកដល់សម្រាកអីចឹង មានប្រជុំអីប្រាប់អត់ទេ?

ទុំៈ អត់ៗ! អត់មានប្រជុំអីផង ។ ប្រហែលជាគេប្រជុំអ្នកធំៗហ៊ីក៏មិនដឹង បើខ្ញុំនៅតូចជាងគេអត់បាន ។

ដានីៈ អាយុប៉ុន្មានកាលហ្នឹង?

ទុំៈ ខ្ញុំកាលហ្នឹង មិនទាន់ដល់២០ទេកាលហ្នឹង យ៉ាងច្រើន១៥,១៦ដឹង ។

ដានីៈ ចឹង?

ទុំៈ ហ្នឹងហើយ ។

ដានីៈ ដល់ពេលមកសម្រាកនៅសិរី្ធមួយយប់ ហើយបានឡើងរទេះភ្លើងមក ។ ដល់ពេលឡើងរទេះភ្លើងមក មកគ្នាច្រើនទេ?

ទុំៈ មកគ្នាច្រើន ។

ដានីៈ ពីណាខ្លះកាល មីងមាននៅចាំទេ?

ទុំៈ អត់ស្គាល់ទេ អត់ចាំទេដូចថានៅតូចៗ គេមកដូចថាមកផ្សេងៗគ្នាចឹងធ្វើម៉េចបានស្គាល់គេ ។

ដានីៈ កាលហ្នឹងមានបងជីដូនមួយឈ្មោះ សន អីហើយអ្នកផ្សេងៗទៀតមានទេកាលហ្នឹង មានផ្សេងទៀតជិះរទេះភ្លើងមកជាមួយគ្នាទេ?

ទុំៈ ជិះមកជាមួយគ្នាជិះ ប៉ុនខ្ញុំអត់ស្គាល់គេ ។

ដានី៖ ជិះច្រើន?

ខ្ញុំ៖ ចាស! ប៉ុនមិនស្គាល់ទេ។

ដានី៖ កាលហ្នឹងអ៊ីចែម គាត់មកជាមួយដែរអត់? គាត់មានជិះរទេះភ្លើងមកជាមួយគ្នាដែរអត់ទេ?

ខ្ញុំ៖ វាមិនទេកាលហ្នឹង មិនដឹងជាយាយចែម គាញ៉េនហ្នឹងមកជាមួយគ្នាអត់ទេ បើខ្ញុំអត់នេះដែរ បើជិះ ព្រោះអីជិះវាខុសគ្នាចឹង ខ្ញុំអត់បានឃើញគាត់ឃើញអីផង។

ដានី៖ អត់បានឃើញទេ ពេលជិះរទេះភ្លើ?

ខ្ញុំ៖ ចាស! ទើបមកឃើញគាត់នៅអីភ្នំលាបហើយស្វាយហ្នឹងតា។

ដានី៖ ហ្ហូ!ចឹងទេហ៎?

ខ្ញុំ៖ ចាស! អត់ដែលឃើញទេ ទើបតែមកឃើញគាត់នៅឯស្វាយនេះ។

ដានី៖ ចឹងដល់ពេលអឺជិះ មកជាមួយគេ អឺអត់ស្គាល់គេទេ ស្គាល់តែបងស្រីមួយទេ?

ខ្ញុំ៖ ចាស!

ដានី៖ ហើយដល់ពេលជិះ ពីហ្នឹងមក មកឈប់នៅឯណាទៅ ពីតាកែវ?

ខ្ញុំ៖ មកឈប់នៅ ជិះពីតាកែវមកឈប់នៅភ្នំពេញ។

ដានី៖ ឈប់នៅភ្នំពេញសិន?

ខ្ញុំ៖ ចាស!

ដានី៖ ឈប់នៅភ្នំពេញ ឈប់នៅម្តុំណា?

ខ្ញុំ៖ អត់ស្គាល់ អត់ស្គាល់រលីង។

ដានី៖ ចាំមើលយើងមកដល់កន្លែងភ្នំពេញ មានរ៉ារទេះភ្លើង រ៉ាហើយយើងមានចេញពីរ៉ាទៅសម្រាក នៅឯណាដែលអត់ទេ?

ខ្ញុំ៖ គេឲ្យសម្រាក ប៉ុនមិនដឹងកន្លែងនៅត្រង់ណា សម្រាកហ្នឹងនៅក្បែរមាត់ទឹក។

ដានី៖ ក្បែរមាត់ទឹក?

ខ្ញុំ៖ ចាស!

ដានី៖ ក្បែរមាត់ទឹក ទឹកទន្លេ?

ខ្ញុំ៖ ទឹកទន្លេ។

ដានី៖ ជិតវាំង?

ខ្ញុំ៖ មិនដឹងត្រង់ណា ពេលចេញទៅឃើញទឹក ចុះពីផ្ទះទៅ ឃើញទឹកតែម្តង។

ដានី៖ ទឹកហ្នឹង បានន័យថាទន្លេមេគង្គ ទន្លេសាបហើយ ទន្លេបាសាក់ហើយយ៉ាងម៉េចអីដែរ?

ទុំៈ មិនដឹងត្រង់ណាទេ ។

អ្នកលជិតខាងៈ ទឹកវែង ឬក៏ទឹកខ្វី?

ទុំៈ ទឹកវែងណា! មកភ្នំពេញចុះពីផ្ទះទៅមើលទៅឃើញទឹកវែង ប៉ុនមិនដឹងត្រង់ណាព្រោះខ្ញុំនៅតូចៗដែរ ។

ដានីៈ បាទ! ហើយដល់ពេលទៅសម្រាកនៅកន្លែងផ្ទះនៅភ្នំពេញហ្នឹង បានប៉ុន្មានយប់បានគេឲ្យបន្តមកទៀត?

ទុំៈ ដឹងថាបានប៉ុន្មានយប់ទេ កាលហ្នឹង! បើមិន៣, ៤យប់បានគេឲ្យចេញមកវិញ ។

ដានីៈ សម្រាកនៅ ភ្នំពេញហ្នឹងមានគេធ្វើអីខ្លះទៅនៅភ្នំពេញ?

ទុំៈ អត់ៗ! មានធ្វើអីទេ បើខ្ញុំនៅតូចចឹង ពេលមកតាមគេចឹងអត់ដឹង បើគេអ្នកធំៗអីគេធ្លាប់ធ្វើការតែម្ដងក្រែងគេដឹង បើខ្ញុំនៅតូចៗចឹងអត់ដឹងទេ ។

ដានីៈ ៣, ៤យប់ចឹង អ៊ំនៅផ្ទះតែម្ដង ឬក៏គេឲ្យធ្វើការអីដែរ?

ទុំៈ អត់ៗ អត់មានបានធ្វើការអីផង ។

ដានីៈ នៅផ្ទះហ្នឹង! គ្នាច្រើនទេ សម្រាកហ្នឹង?

ទុំៈ នៅសម្រាកហ្នឹង គ្នាច្រើនតាំ ។

ដានីៈ ប្រហែលប៉ុន្មានទៅ?

ទុំៈ ដូចក្នុង១កន្លែងយើងនៅសម្រាកចឹង គ្នាប្រហែល១០នាក់ចឹងទៅ ខាងនោះ៣,៤,១០នាក់ចឹងទៅជាប់ៗគ្នាហ្នឹង ។

ដានីៈ ចុះបងជីដូនមួយរបស់អ៊ំឈ្មោះ សន គាត់នៅជាមួយដែរ ឬក៏គាត់ទៅសម្រាកនៅកន្លែងផ្សេង?

ទុំៈ គាត់ហើយ ទៅកន្លែងផ្សេងទៅ មកៗជាមួយគ្នា ។

ដានីៈ អត់ទេ! កាលនៅភ្នំពេញណាំ?

ទុំៈ ភ្នំពេញនៅជាមួយគ្នា ។

ដានីៈ គាត់នៅជាមួយជាប់រហូតដដែរ ឬក៏គាត់ទៅប្រជុំអីដែរ?

ទុំៈ គាត់មក ប្រជុំអីខ្ញុំអត់ដឹងដែរ ប៉ុនមកដល់ភ្នំពេញហ្នឹងក៏បែកផ្លូវគ្នាទៅ គេមកក្រោយគេមកមុន ។

ដានីៈ ពីណាមកក្រោយ?

ទុំៈ បងខ្ញុំហ្នឹង! ខ្ញុំមកជាមួយគាត់នេះមុន គាត់យកមកនៅជាមួយ ។

ដានី៖ ចឹងពេលទៅដល់ភ្នំពេញ មីងបានជួប?

ខ្ញុំ៖ ជួបៗបង ផល ។

ដានី៖ ផលប្រពន្ធអ៊ីប្រុសមុនហ្នឹង?

ខ្ញុំ៖ ចា៎ស!

ដានី៖ ជួបគាត់ពេលណាហ្នឹង?

ខ្ញុំ៖ ជួបពេលគាត់មកដល់អើយបាត់ដំបង មកភ្នំពេញមកជួបគ្នាចឹងមករហូតមកជាមួយគ្នាហ្នឹង មកដល់នេះបានបែកគ្នា ដល់ភ្នំពេញ ខ្ញុំចេញមកជាមួយគាត់ គេចេញទៅនោះទៅដល់មកដល់បាត់ដំបងមកជួបគ្នាមួយសារទៀត ខ្ញុំមកនេះមក គេទៅអន្លង់វិលទៀតទៅ ដល់មកជំនាន់ហ្នឹងគេទៅផ្ទះវិញទៅ ឯខ្ញុំមកជួបគាត់នៅនេះទៅ ។

ដានី៖ បាទ! អ៊ីទេចង់និយាយថាពេលដែលអ៊ីចេញមកពីតាកែវមក មកជាមួយបងជីដូនមួយឈ្មោះសន ចឹងមកដល់ភ្នំពេញ អ៊ីបានជួបប្រពន្ធអ៊ីប្រុសមុនគាត់ឈ្មោះ ផលនៅភ្នំពេញ ហើយជួបទៅអ៊ីស្គាល់ជាមួយគាត់ ឬយ៉ាងម៉េច?

ខ្ញុំ៖ ស្គាល់! គាត់ហៅនៅជាមួយ ។

ដានី៖ ស្គាល់ពីអន្កាលមក?

ខ្ញុំ៖ ស្គាល់ចេញមកជាមួយគ្នាហ្នឹង ខ្ញុំមកជាមួយគាត់ ។

ដានី៖ ចេញជាមួយពីអន្កាល?

ខ្ញុំ៖ ចេញមកពីផ្ទះមកពីឆ្នាំ៧៨ហ្នឹង ដល់មកជួបក៏គាត់ឃើញខ្ញុំ ។

ដានី៖ ហ៊ូ! ជួបគ្នានៅលើរទេះភ្លើងពេលចេញពីសិទ្ធមកហ្នឹង?

ខ្ញុំ៖ ចា៎ស! ពេលគាត់ឃើញខ្ញុំក៏គាត់ស្រលាញ់ខ្ញុំ ហៅមកជាមួយមក ។ គាត់ឃើញខ្ញុំតូចហ៎! ហៅមកជាមួយគ្នាមកជាមួយបងខ្ញុំរហូត ហើយបានបែកគ្នា ។

ដានី៖ មកដល់ភ្នំពេញហ្នឹង ចាប់ផ្តើមបែកគ្នា កាលហ្នឹងគាត់ហៅមកជាមួយចុះបង បងស្រីគាត់អត់ថាអីទេ?

ខ្ញុំ៖ បងស្រីអត់ អត់មានថាអីផង ។

ដានី៖ គាត់ហៅមកជាមួយ កាលហ្នឹងគាត់ធ្វើអីកាលហ្នឹង?

ខ្ញុំ៖ នេះហ៎?

ដានី៖ បាទ!

ទុំៈ ប្រពន្ធគាត់អត់មានធ្វើអីទេ បើគ្រួសារគាត់មកពីនោះ មកក៏មិនទាន់បានដឹងធ្វើដែរ ដល់មកដល់នេះបាន មកដល់នេះខ្ញុំចេញជាមួយប្រពន្ធគាត់ទៅនៅភូមិទឹកថ្លាទៅ គាត់មកនៅម្នាក់តែម្នាក់គាត់ ។

ដានីៈ ម្នាក់នៅឯណា?

ទុំៈ ម្នាក់នៅស្វាយហ្នឹង ។

ដានីៈ បាទ! ចឹងដល់ពេលចេញពីឆ្នាំ៧៨មក អីបែកពីបងស្រីមក មកជាមួយឈ្មោះដលហ្នឹង?

ទុំៈ ចា៎ស!

ដានីៈ កាលហ្នឹងមកគ្នាច្រើនទេមកជាមួយដលហ្នឹង?

ទុំៈ មកដូចថាមកគេគ្រប់កន្លែង មកគ្នាច្រើនប៉ុនគ្រាន់តែវាមកចូលគ្នា គេមកកន្លែងគេខ្លះ ខ្លះកន្លែងយើងមកជុំគ្នាចឹងទៅជាមួយគ្នាចឹងទេ ។ ប៉ុនមកកន្លែងមិនជាបែកគ្នាទៅកន្លែងណាអស់ទៅ ។

ដានីៈ ចឹងមកស្នាក់នៅឯភ្នំពេញ៣ថ្ងៃទេ ប៉ុន្មានថ្ងៃ?

ទុំៈ ខ្ញុំមិនដឹងប៉ុន្មានយប់ មកស្នាក់កន្លែងហ្នឹង មិនដឹង៣,៤ក៏មិនដឹង ឬក៏២យប់ក៏មិនដឹង នៅតូចដែរ វាមិនចាំទេ យូហើយ ។

ដានីៈ ហើយដល់ពេលយើងជិះរទេះភ្លើងភ្នំពេញមក មកចុះនៅត្រង់ណា?

ទុំៈ ចុះមកពីភ្នំពេញ មកបាត់ដំបង ។

ដានីៈ មកបាត់ដំបងចុះនៅម្តុំណាទៅ?

ទុំៈ បាត់ដំបង មិនដឹងកន្លែងណាទេ មិនស្គាល់ផង ។

ដានីៈ បាទ! ចុះមកបាត់ដំបង ។ ចុះបាត់ដំបងទៅណាទៀត?

ទុំៈ ហើយមកស្វាយ មកស្វាយជិះឡាន ។

ដានីៈ ជិះពីបាត់ដំបងមកស្វាយ ជិះឡាន?

ទុំៈ ចា៎ស!

ដានីៈ ចឹងចុះ ពេលចុះមក ចឹងនៅបាត់ដំបង មានបានសម្រាកទេ?

ទុំៈ គាត់នៅបាត់ដំបង ម៉េចទេដឹងបានសម្រាកដែរទេអត់ អត់ទេម៉េចកាលហ្នឹង!

ដានីៈ ចេញពីរទេះភ្លើងយើងមក យើងជិះឡានមកស្វាយតែម្តង ឬក៏យើងសម្រាកនៅបាត់ដំបងសិន ។

ទុំៈ អត់ទេ! ដូចជាស្នាក់នៅបាត់ដំបងដែរ ។

ដានីៈ ស្នាក់នៅម្តុំណា?

ទុំៈ អត់ចាំកន្លែង ។ គាត់ស្នាក់ហ្នឹង មិនដឹងស្នាក់ប៉ុន្មានយប់ទៀតមកដល់បាត់ដំបងហ្នឹង ។

ដានី៖	មានទៅអាកន្លែងផ្ទះគេផ្ទះទឹករលកទេ ដំបូលទឹករលក មានទៅហ្នឹងដែលអត់ទេ?

ខ្ញុំ៖	ហាំ អត់ដឹងទេ ។

ដានី៖	ពួកគេ ចំណាំគេថាផ្ទះទឹករលកៗ?

ខ្ញុំ៖	អត់ស្គាល់!

ដានី៖	អត់ស្គាល់ទេ!

ខ្ញុំ៖	អត់ស្គាល់ទេ ប៉ុនដើរដឹងថាកន្លែងសម្រាកកអី ចេះតែដឹងប៉ុនដល់ថាពេលសួរកកន្លែងទឹករលក ទឹកអីអត់ស្គាល់ទេ ។

ដានី៖	បាទ! ចឹងដល់ពេលអ៊ីជិះឡានមក ជិះមកជាមួយពីរនាក់បងផលហ្នឹងហើយក៏មានគ្នាច្រើនទៀត?

ខ្ញុំ៖	គេមកគ្នាច្រើនទៀត ។

ដានី៖	បើតាមស្គាល់កាលហ្នឹងពីណាខ្លះទៀតទៅ?

ខ្ញុំ៖	គ្រាន់តែខ្ញុំវាអត់ស្គាល់គេ ដូចខ្ញុំប្រាប់ចឹងថាគេមកពីភូមិនោះៗចឹងហើយអត់ស្គាល់ ។ គ្រាន់តែមករួមជាមួយហ្នឹងគេហ្នឹងណា ។

ដានី៖	ប៉ុន្មានឡានទៅគ្រាន់តែចេញពីស្វាយ ពីបាត់ដំបងមកស្វាយ ។

ខ្ញុំ៖	ពីបាត់ដំបង អើយមកអាជិះឡានគេមួយ ប៉ុនពេញ ។

ដានី៖	ឡានហ្នឹង ឡានអីគេ?

ខ្ញុំ៖	ឡានហ្នឹងខៀវ ឡានពណ៌គ្រាប់ឪឡឹកនឹង ។

ដានី៖	កាលហ្នឹង បងផលមកហ្នឹង គាត់ការជាមួយគ្នានៅ?

ខ្ញុំ៖	ការហើយ បានខ្ញុំបានគាត់ហៅខ្ញុំនៅជាមួយ ។

ដានី៖	ចឹងគាត់ការហើយ ប៉ុន្តែគាត់មានកូននៅ?

ខ្ញុំ៖	គាត់ទើបតែមានកូនមកនៅនេះហ្នឹង ។

ដានី៖	មកនៅស្វាយហ្នឹង?

ខ្ញុំ៖	ហ្នឹងហើយ! មាននៅស្វាយហ្នឹងឯង ។

ដានី៖	ចឹងកាលហ្នឹង គាត់មកពីរនាក់ប្តីប្រពន្ធគាត់មកជាមួយគ្នា?

ខ្ញុំ៖	ចាំស!

ដានី៖	ពេលមកជាមួយគ្នា ស្គាល់អ៊ីពេលជិះរទេះភ្លើងហ្នឹង គាត់មកពីរនាក់ប្តីប្រពន្ធគាត់ហើយ?

ទុំៈ ចាស! ពេលហ្នឹងគាត់មកហើយ ពេលគាត់ឃើញខ្ញុំ ថាដូចឃើញខ្ញុំចឹង គាត់ស្រលាញ់ គាត់ថាដូចប្អូនគាត់ក៏ហៅទៅមួយទៅ អាហ្នឹងដូចគេថា ខ្ញុំនៅនិរសាគាត់ហ្នឹងទេណា! ហើយនៅជាមួយគាត់ជាប់ទៅ បានគេថានិរសារគាត់ហ្នឹង ។

ដានីៈ ចឹងដល់ពេលនៅជាមួយគាត់ទៅ គាត់ឲ្យធ្វើនិរសាគាត់ទៅ?

ទុំៈ ចុះមានធ្វើនិរសាអីទេ ប៉ុនគេហៅនិរសាចឹងបណ្ដោយទៅ វាគ្មានធ្វើអីផងៗ

ដានីៈ បាទ! ចឹងពេលដែរជិះឡានមកដល់ស្វាយដំបូង អឹទៅស្នាក់នៅឯណាទៅ?

ទុំៈ ដល់ស្វាយកន្លែងស្នាក់នៅ មិនដឹងកន្លែងខ្ញុំត្រង់ណា! ត្រង់ហ្នឹងមានសាលាគេ ហើយគេដាក់មានពាង ដុះគ្របមិនដឹងជាដើមជ្រៃ ឬក៏ដើមអីក៏ម៉េចទេ មិនដឹងត្រង់ណាទេ ឃើញមានត្រង់ហ្នឹងមានរោង រោងគេហ្នឹង គេទៅអាចេះមួយខ្ទង អាចេះមួយខ្ទង ប៉ុនដឹងត្រង់ណាទេអត់ស្គាល់ ។ មើលទៅដូចដើមជ្រៃ ។

ដានីៈ ម្តុំណាទៅៗ?

ទុំៈ អាហ្នឹងចូលដំបូង ហើយមើលដូចជារានព្រៃ ។

ដានីៈ ដល់ពេលអឹមានប្រសាសន៍មិញ ដល់ស្វាយគាត់ពីនាក់ប្តីប្រពន្ធគាត់ គាត់អត់នៅជាមួយគ្នាទេ?

ទុំៈ អត់ទេ! នៅបែកគ្នា ។

ដានីៈ នៅបែកគ្នា

ទុំៈ ចាស! គាត់នេះនៅខាងទឹកថ្លា ខ្ញុំនៅជាមួយគាត់នៅខាងទឹកថ្លា ហើយគាត់នៅម្កាក់ នៅភូមិម្កាក់ ។

ដានីៈ គាត់នៅម្កាក់ ដល់ពេលអឹហើយហ្នឹងប្រពន្ធគាត់ឈ្មោះដល នៅទឹកថ្លា ។ នៅទឹកថ្លាធ្វើអីទៅ?

ទុំៈ នៅជាមួយគាត់ ដឹងគាត់ធ្វើអីទៅ បើឃើញគាត់ចុះស្រែទៅជាមួយគាត់ទេ ។

អ្នកជិតខាងៈ ចម្ការកប្បាស ។

ដានីៈ គាត់នៅគ្រប់គ្រងចម្ការកប្បាសមែនទេ?

ទុំៈ អត់មានកប្បាសណាគាត់ នៅខាងស្រែ នៅធ្វើស្រែធ្វើអីជាមួយគេហ្នឹង ។ ព្រលឹមចុះទៅស្រែទៅហ្នឹងគេទៅ ។

ដានីៈ ចុះអឹប្រុសផាត មកម្កាក់មកនៅធ្វើអី?

ទុំៈ នៅខាងម្កាក់ដឹង គាត់ធ្វើភូមិមិនដឹង ធ្វើឃុំមិនដឹង! ដឹងអីគាត់នៅខាងហ្នឹង ហើយខ្ញុំនៅខាងទឹកថ្លានោះ ។

ដានីៈ គាត់នៅគណៈតំបន់៥ ឬក៏មិនមែន ។

ទុំៈ តំបន់៥ មែនទេដឹង! ខ្ញុំមិនសូវចាំផង ប៉ុនដល់គេហៅចឹង ដឹងថា ។

អ្នកជិតខាងៈ សុំកាត់តិចចុះ ព្រោះគាត់និយាយជាមួយខ្ញុំមិញ គាត់ធំគាត់ចូលជួបប៉ុលពតបាន យាយ ថែមអី ។

ដានីៈ ចុះកាលជំនាន់អឹ ទៅ អ៊ីស្គាល់តារិនអត់? ដែលពូឈ្មោះតារិនទេ?

ទុំៈ អត់ស្គាល់ទេ!

អ្នកជិតខាងៈ តាវៀម ។

ទុំៈ បើតាវៀម ស្គាល់! ស្គាល់វត់ហើយហ្នឹង ។

ដានីៈ អត់ទេ! ពេលមុនទៅដល់ស្វាយហ្នឹងតារិន គាត់អត់ទាន់នៅទេចឹងហ៎?

ទុំៈ អត់ទេៗ! អត់ស្គាល់ផង ។

ដានីៈ អត់ស្គាល់តារិនទេ ។

អ្នកជិតខាងៈ ពួកគាត់និរតី ។

ដានីៈ តាហឹង្ស ស្គាល់តាហឹងអត់?

ទុំៈ អត់! អត់!

ដានីៈ អត់ដែលឮឈ្មោះតាហឹង្សទេ?

ទុំៈ អត់! អត់ស្គាល់ទេ ខ្ញុំមេធំៗអត់ស្គាល់ទេ ។ បើខាងគ្រួសារខ្ញុំគាត់ចេះតែដើរ អាហ្នឹង គាត់ចេះតែស្គាល់ហើយ បើខ្ញុំអត់ទេ ។ ខ្ញុំបើនៅឯណាហ្នឹងហើយ ទាល់សព្វថ្ងៃក៏ចឹងដែរ បើថានៅផ្ទះ នៅផ្ទះខ្ញុំអត់ដែលដើរទេ ។

អ្នកជិតខាងៈ គាត់ខស្សរាប់និយាយប្រាប់ខ្ញុំ កាលនៅរស់ថាមកដល់ស្វាយស៊ីសុផនទៅនៅឯម្នាក់ហ្នឹង គាត់ធ្វើគណៈស្រុកជាមួយតារិន តារិនបងតារុំ គាត់ធ្វើនៅគណៈស្រុក ដល់ ។

ដានីៈ គាត់គណៈស្រុកអីគេ? គណៈស្រុកសេរីសោភ័ណ្ឌ ឬក៏យ៉ាងម៉េច?

អ្នកជិតខាងៈ ពីមុនសេរីសោភ័ណ្ឌ ឥឡូវនោះ តារិនស្លាប់បាត់ហើយ ។

ដានីៈ គាត់ស្លាប់ពីអន្កាល?

អ្នកជិតខាងៈ ពូឪខ្ញុំគាត់ប្រាប់ខ្ញុំដែរថា ស្លាប់យូរដែរហ្នឹងតាំងពីនេះ ប៉ុន្តែតារិននោះ គាត់ប្រធានគណៈ តំបន់ គាត់អនុប្រធាន ។

ដានីៈ តារិន គាត់គណៈតំបន់ ហើយគាត់អនុប្រធាន?

អ្នកជិតខាងៈ បាទ!

ទុំៈ ចុះបើគាត់ដើរ បានគាត់ដឹង ។

ដានី: ចឹងកាលហ្នឹងអ៊ំអត់ដឹងថាគាត់ធ្វើ អើ! អនុរបស់តារិនទេ?

ខ្ញុំ: អត់ទេ! អត់ដែលស្គាល់ទេ ។ បើថានៅកន្លែងផ្សេងទៀតធម្មតាឲ្យធ្វើម៉េចដឹងទៅបើ ។

ដានី: ចឹងបើប្តីប្រពន្ធគាត់នៅកន្លែងខុសគ្នា ចឹងគាត់ជួបគ្នាយ៉ាងម៉េចទៅចឹង?

ខ្ញុំ: ដឹង! បើគាត់ទៅលេងខាងប្រពន្ធគាត់ គាត់ទៅមួយយប់ទៅក៏គាត់មកវិញទៅ ហើយបើប្រពន្ធគាត់មកលេងខាងឪគេហ្នឹង គេមកលេងមួយយប់ខ្ញុំនៅផ្ទះនោះ ខ្ញុំមិនដែលបានមកជាមួយទេ ។

ដានី: ហើយប្រពន្ធគាត់អើ! អ៊ំអត់ដឹងថាគាត់ធ្វើអីដែរ? ចុះគាត់មានដែលនិយាយប្រាប់ទេ?

ខ្ញុំ: ខ្ញុំមិនចាំដែរឃើញតែគាត់ធ្វើការហ្នឹង មិនដឹងថាគាត់ធ្វើអី ។

ផេង: រឿងប្រពន្ធរបស់ គាត់ពុំសូវនិយាយប្រាប់ គាត់ប្រាប់តែរឿងផ្ទាល់ខ្លួនគាត់ ។

ដានី: ចឹងគាត់ធ្លាប់ប្រាប់ពីប្រវត្តិគាត់ដែលចឹងហ៎?

ផេង: បាទ! ប្រាប់តែពីប្រវត្តិរបស់គាត់ ។ គាត់ចេញមកគាត់ធ្វើការនៅកន្លែងណាតាំងពីគ្រប់គ្រងម៉ាស៊ីនទឹក ធ្វើស្រែ ធ្វើអីនោះ ។

ដានី: ចុះបងកូនគាត់បង្កើត?

ផេង: បាទ! កូនទីមួយ ។

ដានី: កូនបងគេ? បងឈ្មោះ អីគេ?

ផេង: ឈ្មោះ ផេង, គាត់ប្រាប់ពីប្រវត្តិរបស់គាត់ ។

ដានី: ឈ្មោះ ផង! អីផេង? រស់ ផេង?

ផេង: ទេ! ឈ្មោះ ណន ផេង ។

ខ្ញុំ: ខ្ញុំម្នាកហើយ បានគេឲ្យខ្ញុំទៅពេទ្យវិញ ទៅពេទ្យបាត់ដំបងវិញ ។

ដានី: ចឹងគាត់និយាយប្រាប់ថាតារិន ធ្វើប្រធាន គាត់ធ្វើអនុ ។

ផេង: នេះហើយ បានតារិនបញ្ជូនគាត់ទៅនេះណ៎ ម្នាក់ ។

ដានី: បញ្ជូនទៅនៅម្នាក់?

ផេង: បាទ! ម្នាក់ស្វាយចេក ។

ដានី: ម្នាក់នៅស្វាយចេកវិញ?

ផេង: នៅជាប់សេរីសោភ័ណ្ឌ ។

ខ្ញុំ: ម្នាក់យើងចេញពីស្វាយមក ។

ជេង៖ ដល់ពេលគេនិយាយប្រាប់រឿង ដល់ពេលកាលហ្នឹងគាត់ផ្ដាច់ខ្លួន៩៦ហ៎! សមាហរណ៍កម្ម ៩៦គាត់ឲ្យខ្ញុំទៅលេងឯផ្ទះ គាត់ឲ្យទៅដល់ម្ដាក់ហ្នឹង គាត់ប្រាប់ផ្ទះពីខាងកើតវត្តម្ដាក់ នឹងផ្ទះក្បឿងពីរខ្នងផ្ទះគាត់ ហ្នឹងផ្ទះគាត់ហើយ ។ ដល់ខ្ញុំទៅ ឃើញផ្ទះហ្នឹង ផ្ទះហ្នឹងទើបតែរុស ។

ដានី៖ គាត់ដែលទៅទេតាំងពីផ្ដាច់ខ្លួនមក?

ជេង៖ ទៅ! ខ្ញុំទៅលេង សុំគាត់ទៅប៉ុន្មានទៅ១អាទិត្យ ឡើងទៅកន្លះខែ ។

ដានី៖ ចុះមានស្គាល់គេដែរនៅហ្នឹង?

ជេង៖ ទៅលេង!

ខ្ញុំ៖ វាមានស្គាល់ណា ប៉ុនហើយក៏ទៅ ។

ជេង៖ ទៅដំបូងមានដែលស្គាល់ទេ! ប៉ុន្តែគាត់មានប្រាប់ចំណុចឲ្យទៅ ។

ដានី៖ គាត់ឲ្យទៅមើលអ្វីដែលគាត់និយាយប្រាប់ ថាទៅមើល នៅដូចដើមអីចឹង?

ជេង៖ បាទ!

ដានី៖ ខ្លួនគាត់ គាត់អត់ដែរទៅទេចឹង?

ជេង៖ គាត់ដំបូងគាត់ថាអត់ទាន់ទៅ ទៅឲ្យខ្ញុំទៅមើលមុន ។

ដានី៖ ចុះបងអាយុប៉ុន្មានហើយឥឡូវ?

ជេង៖ ៣៣ហើយ ។

ដានី៖ កើតក្រោយ៧៩ចឹង?

ខ្ញុំ៖ ក្រោយ! ឆ្នាំ៨០វា ។

ដានី៖ ចុះកាលហ្នឹង អ៊ីស្គាល់ អ៊ីថែមដែរ?

ខ្ញុំ៖ អ៊ីថែមទើបតែស្គាល់មកនៅស្វាយហើយហ្នឹងអ៊ី កាលមកពីផ្ទះអត់ដឹងទេ ។

ដានី៖ ស្គាល់យ៉ាងម៉េច ពេលហ្នឹងបានអ៊ីជួបគាត់ ស្គាល់គាត់?

ខ្ញុំ៖ កាលហ្នឹង គាត់មកកន្លែងនៅស្វាយកកន្លែងនេះខ្ញុំនៅនេះហ្នឹងណា អាហ្នឹងគេមក ដឹងកន្លែងគេប្រជុំគេមិនដឹង ខ្ញុំទៅជួបហ្នឹង មកពីនេះ មកពីទឹកថ្លា ។

ដានី៖ មកពីទឹកថ្លាជាមួយបងជល ដើរជាមួយគាត់មក?

ខ្ញុំ៖ ចា៎ស!

ដានី៖ គាត់មកប្រជុំកន្លែងហ្នឹងទាំងអស់គ្នា?

ខ្ញុំ៖ គាត់នៅជុំទាំងអស់គ្នានៅហ្នឹង ហើយគាត់ប្រជុំអីអត់ដឹងទេ ដល់ចូលកន្លែងហ្នឹងគេអត់ឲ្យចូលទេ ។

ដានី៖ កន្លែងនៅម្ដុំណាទៅ ប្រជុំហ្នឹង?

ខ្ញុំៈ ផ្ទះក្បឿង! មិនដឹងផ្ទះក្បឿងកន្លែងណា ។

ដានីៈ ហើយកាលហ្នឹង ដឹងថាអ៊ីចែមគាត់ធ្វើអី?

ខ្ញុំៈ អត់ដឹង! ចុះបើគាត់មិនមែននៅជិតផង ។

ដានីៈ ចុះកាលហ្នឹងអ៊ីចែម ប្ដីគាត់ឈ្មោះអី?

ខ្ញុំៈ យាយចែមប្ដីគាត់ឈ្មោះតាញ៉ែន ។

ដានីៈ តាញ៉ែន ធ្លាប់ស្គាល់គាត់ទេ?

ខ្ញុំៈ តាញ៉ែន ស្គាល់មកនៅ! កាលពីនៅស្រុកនោះ ខ្ញុំអត់ស្គាល់ទេ ស្គាល់តែបងរិនទេ ដល់ពេលថា បងប្អូនម៉ែឪគាត់ហ្នឹង បានមកស្គាល់មកត្រឹមនៅម្ដាក់ទេ ហើយគាត់នៅភ្នំលាប នៅភ្នំលាបហ្នឹង មកនៅម្ដាក់បានខ្ញុំស្គាល់ត្រឹមហ្នឹង ។

ដានីៈ ស្គាល់ពីណាគេ?

ខ្ញុំៈ ស្គាល់តាញ៉ែនហ្នឹង

ដានីៈ តាញ៉ែន គាត់នៅឯណា នៅភ្នំលាប?

ខ្ញុំៈ នៅភ្នំលាបហ្នឹង, ភ្នំលាបចឹងហើយ អ្នកក្នុងស្រុកចឹងហើយ តែដល់ពេលសួរៗទៅបានគាត់ថា នៅក្បាលអូរ ពីមុនអត់ដឹងផងហ្នឹង ទើបតែដឹង ដល់ពេលគាត់មកជួបនៅហ្នឹង បានខ្ញុំសួរគាត់ ហើយគាត់ថានៅក្បាលអូរ បានដឹង ។

ដានីៈ គាត់ប្រាប់ថា គាត់នៅក្បាលអូរ?

ខ្ញុំៈ ចា៎ស! ហើយខ្ញុំមានដែលស្គាល់ណា! ទាល់តែមកជួបហ្នឹងសួរគាត់បានដឹងថាគាត់នៅក្បាលអូរ ហ្នឹង ។

ដានីៈ គាត់នៅក្បាលអូរ! ហើយចឹងតាញ៉ែន គាត់មែននៅខាងស្វាយ ខាងអីដែលអ៊ីថានេះស្គាល់គ្នា គាត់នៅអីខាងភ្នំលាបទេ?

ខ្ញុំៈ ខ្ញុំដឹងថាគាត់នៅភ្នំលាប តែមិនដឹងថាគាត់នៅត្រង់ណាទៀតទេ ទើបតែដឹងចុងក្រោយថាគាត់នៅ ភ្នំលាបណា គាត់មកលេង ។

ដានីៈ គាត់ខស្សាហរណ៍ឡើងមកប្រជុំនៅស្វាយដែរ?

ខ្ញុំៈ ខ្ញុំអត់បានមកស្វាយផង បានអីជួបគាត់ ។

ដានីៈ អ៊ីចែមអីគាត់ខស្សាហរណ៍មកស្វាយដែរ?

ខ្ញុំៈ ចា៎ស!

ដានីៈ ធ្លាប់ជូននៅស្វាយដែរ?

ទុំ៖ ចាស! បើយាយថែមនោះគាត់មិនស្គាល់ បើតាញ៉ែននោះក្រែងលោគាត់ថាស្គាល់ តែបើថាកូនគាត់ ។

ដានី៖ ចុះបើឪពុកម្ដាយគាត់ កាលខ្ញុំជួបគាត់ ដឹងថាឪពុកម្ដាយគាត់មកនៅជាមួយដែរ?

ទុំ៖ អត់ អត់ដឹង!

ដានី៖ ចុះអ៊ឹ អ៊ឹស្រីមិញគាត់នៅជាមួយបងប្អូនគាត់ហ្នឹងដែរហ៎?

ទុំ៖ ចាស! គាត់នៅជាមួយកូន ។

ដានី៖ គាត់មកនៅស្វាយជាមួយគ្នាដែរ?

ទុំ៖ អត់ទេ! គាត់នៅស្រុកណា គាត់ទើបតែមកនៅផ្លូវនេះហ្នឹង នឹងមកលេងកូនហ្នឹងណា ។

ដានី៖ ហ្ន៎! មកលេងកូនទេហ្នឹង?

ទុំ៖ ចាស! គាត់អត់មានស្រុកកំណើតនៅនេះទេ គាត់នៅស្រុកទេសយើង ។

ដានី៖ កាលជំនាន់ឆ្នាំ៧៨អ៊ី គាត់អត់មកលេងជាមួយយើង?

ទុំ៖ មកតែខ្ញុំ មកជាមួយគាត់ជាប់គ្នាតែ៣នាក់ហ្នឹង ដូចបងប្អូន ដល់តែពេលគាត់ស្លាប់ទៅរត់ទៅជុំហ្នឹង ក៏តាៗគាត់និយាយគាត់នាំឲ្យយកនៅហ្នឹងទៅ ។

ដានី៖ ចុះគាត់មាននិយាយប្រាប់ថា អនុបន្ទប់ពីគាត់ណា គេដែរអត់ទេ?

ដេង៖ អត់! អត់មានប្រាប់ទេ ។

ដានី៖ គាត់និយាយតែថា តារិនប្រធាន គាត់អនុហើយ!

ដេង៖ គាត់ប្រាប់តែរឿងប្រវត្តិគាត់ប៉ុណ្ណឹងឯង ។

ដានី៖ អត់មានគាត់ប្រាប់ថា សមាជិកគាត់ពីណា គាត់អត់ប្រាប់ទេណ៎?

ទុំ៖ គ្មានដែលដឹងទេ! គ្មានដែលនិយាយប្រាប់ឲ្យដឹងទេ ។

ដេង៖ ថ្ងៃណានេះចឹងទៅ គាត់ហៅប្រាប់តិចៗចឹងទៅណា រឿងប្រវត្តិសាស្ត្រ ។

ដានី៖ គាត់ហើយហ្នឹងអ៊ីថែមពីណាធំជាង?

ទុំ៖ អត់ដឹង! មិនស្រួលយាយថែមក៏មិនដឹង ខ្ញុំមិនដឹងដែរ បើថាយាយថែមធ្វើការដែរយាយថែមធំជាង ចុះបើខ្ញុំអត់ដឹងដែរ ។ ខ្ញុំឃើញតាញ៉ែនដើរទៅមកៗបានខ្ញុំថាប្ដីប្រពន្ធគាត់ ក្រែងលោខាងហ្នឹងដឹងបានគេ!

ដានី៖ ហើយគាត់ដើរទៅមកណា?

ទុំ៖ ឃើញគាត់មកលេងផ្ទះគាត់នៅម្កាក់ ។

ដានី៖ គាត់នៅម្កាក់ដែរ?

ខ្ញុំៈ អត់ទេ! គាត់មកលេងជាមួយគ្រួសារខ្ញុំហ្នឹង មកម្តាក់ហ្នឹង ហ្នឹង!បានថាក្រែងគាត់ធំជាង ចេះតែឃើញមកលេងហ្នឹង ។

អ្នកជិតខាងៈ សុំកាត់បន្តិចបានទេ?

ខ្ញុំៈ ចាស!

អ្នកជិតខាងៈ បើអ៊ឹគិតថាគាត់ធំជាងយាយថែម ខ្ញុំសុំឲ្យយោបល់ខ្ញុំណាស់ ព្រោះគាត់ហៅថាថែមមួយមាត់ហើយ គាត់ជួប ប៉ុល ពត ពួកនេះធំៗច្រើនជាង ហៅមកជួបដូចអ៊ឹថាណាបងណាស់ គេឲ្យទៅនៅឯខេត្តនោះ កន្លែងធំណា តំបន់ណា! ហើយគាត់ហៅអា យាយថែម គាញ៉ែនបានជាខ្ញុំថា គាត់ហៅអាហ្នឹង អឺ...បាននិយាយច្បាស់ ។

ខ្ញុំៈ បើគាត់នោះដែលធ្វើការ ក្រែងលោគាត់ដឹង បើខ្ញុំហ្នឹងណាស់ហើយ ។

ដានីៈ បាទៗ! ហើយចុះដូចឆ្នាំ៧៩យ៉ាងម៉េចទៅ ពេលរត់អីយ៉ាងម៉េចទៅ មាននៅចាំទេ?

ខ្ញុំៈ រត់ហេ៎?

ដានីៈ បាទ!

ខ្ញុំៈ កាល៧៩រត់! ខ្ញុំរត់ប្រជះប្រភីងហ្នឹងគេ អត់បាយអត់ទឹកគេដែរហ្នឹង ។

ដានីៈ កាលហ្នឹងយើងរត់ជុំគ្នា អ៊ឹថែម ប្តីប្រពន្ធគ្រួសារគាត់ យើងរត់មកជុំគ្នាដែរអត់ទេ?

ខ្ញុំៈ អត់ទេ! គាត់បែកចូលខាងនេះ ខ្ញុំរត់ចូលមកបែកខាងនេះវិញ ។

ដានីៈ រត់មកខាងណាវិញ?

ខ្ញុំៈ កាលហ្នឹង! គាត់ថាគាត់នៅខាងស្រុកព្រៃមាន់ ហើយខ្ញុំរត់មកខាងអើយ ស្រះកែវបែកគ្នាយូរ ។

ដានីៈ រត់! បានន័យថាយើងចេញពីស្វាយមកចាក់ទៅខាងស្រះកែវ ដល់ភ្លាមតែម្តង?

ខ្ញុំៈ អត់ទេ! ខ្ញុំចេញស្វាយមក ខ្ញុំមកនៅថ្មពួក ចេញពីថ្មពួកមក មកស្វាយចេក រត់សៀៗតាមហ្នឹងរហូតហ្នឹង ។

អ្នកជិតខាងៈ ខ្ញុំមករទេះ ឬក៏មកឡាន?

ខ្ញុំៈ មានឡានអាបរ រត់ចង់ស្លាប់ រទេះគោផង ។

ដានីៈ កាលហ្នឹង មកថ្មពួកមកជួបពីណាគេ? ជួបតាវៀម?

ខ្ញុំៈ មកថ្មពួក មកជួបតាវៀមនៅ គេហៅ ជិតមកអូរជ្រៅណា៎! មកជិតអូរជ្រៅហើយជួបគាត់ថា គាត់រកឆ្លងទៅអូរជ្រៅ ហើយមកជួបគ្នាហ្នឹងឯង ជួបហើយក៏មកអត់រួចខ្ញុំត្រលប់

ក្រោយវិញ គ្រលប់មកថ្ពួកវិញ។ ពេលខ្ញុំបកមកវិញ មិនយករទេះគោរទេះអី ដល់អត់អីហូន មិនលក់រទេះគោ លក់រទេះអី ថៃទិញនោះ លក់ឲ្យថៃ។

ដានីៈ តាវៀម គាត់នៅថ្ពួកហ្នឹង កាលមុន?

ខ្ញុំៈ អត់ដឹងគាត់នៅឯណាទេ! ប៉ុនទើបរត់ទៅ ទៅជួប ឪគេថាតាវៀមៗហ្នឹងទៅជួបនៅអាកន្លែងផ្លូវថាឆ្នងអូរជ្រៅនោះ ដល់ទៅជួបហ្នឹងដល់បានចេញទៅ ខ្ញុំពួកក៏មកជាមួយគាត់មកមុនទៀតមក។ រទេះគោមកនៅហូរហែរពេញហ្នឹងទាំងអស់។

អ្នកជិតខាងៈ ចុះស្តេចដេកនៅកន្លែងណា ស្តេចនៅសីហនុ?

ខ្ញុំៈ អត់ដឹង!

ដានីៈ គាត់សម្តេចសីហនុ គាត់មកដេកនៅ!

អ្នកជិតខាងៈ អ៊ីផាតគាត់ប្រាប់។

ខ្ញុំៈ អាហ្នឹងខ្ញុំអត់ដឹងទេ!

អ្នកជិតខាងៈ អ៊ីផាតគាត់ប្រាប់ថាស្តេចនៅជាមួយគាត់ គាត់យាម។

ដានីៈ ហើយអ៊ីចុះពេលដែលយើងរត់ រត់ទៅដល់រយៈពេលប៉ុន្មានទៅ ពីស្វាយទៅដល់ស្រះកែវ?

ខ្ញុំៈ ហ៊ូ! រត់ដើរទៅដេកតាម ព្រៃស្បូវតែរហូត ទម្រាំតែថៃគេមកយកទៅ យូរដែរហ្នឹង!

ដានីៈ ហើយយ៉ាងម៉េចទៀតទៅ ពេលដែលយើងទៅដល់ជំរំហើយ?

ខ្ញុំៈ ទៅដល់ជំរំនេះ មានតែឃើញតែបារាំងឃើញអីគេយកអង្ករយកអីមកចែកយើងនោះ ហើយដល់ទៅនៅជំរំហ្នឹង ហើយផ្ញើរកូនខ្ញុំអាមួយនោះ ហើយគ្រលប់មកវិញ ហើយចុះបើទៅនោះវា!

ដានីៈ ចុះពេលរត់ហ្នឹង ប្រពន្ធគាត់ស្លាប់ពេលណា?

ខ្ញុំៈ ស្លាប់បាត់ហើយ! គាត់ស្លាប់ហើយ។

ដានីៈ ស្លាប់ពេលនៅកន្លែងណា?

ខ្ញុំៈ ស្លាប់នៅក្រោយវត្តវ៉ាង នៅឯបឹងត្រកួន។

ដានីៈ បឹងត្រកួន ពេលចេញពីស្វាយទៅ?

ខ្ញុំៈ អត់ទេ! ស្លាប់ មិនមែនចេញពីស្វាយទេ យើងរត់មួយជុំហើយបានគាត់ស្លាប់ យើងរត់ដើរដេកតាមដំណាក់គ្រប់កន្លែងណា ហើយគាត់ឈឺៗ ដើរដាក់ស៊ីរ៉ូមគ្រប់ដំណាក់។ សែងគាត់ដើរដាក់គ្រប់ដំណាក់អស់ពុំតិចទេ ប៉ុនអត់ជា វត្តវ៉ាងនោះ ស្លាប់នៅវត្តវ៉ាង។ អត់ទេ! អាទឹកចេញ

នោះស្លាប់កូន ។ ខ្មោចបងស្លាប់នៅអាកន្លែងដើមមៀនធំ ក្រោយវត្តវ៉ាងបឹងបេងហ្នឹងណា៎ អាដើមមៀនធំ... ។

អ្នកជិតខាងៈ សុំកាត់បន្តិច! ក្រោយពី៧៩ណា៎ នៅហ្នឹងម៉ាឡៃហ្នឹង ងាប់អស់ច្រើនណាស់ អត់បាយ អត់ទឹក រាប់រយអ្នកនៅខែចែត្រ ខែ៤នោះ ។

ទុំៈ យើងរត់អត់មានអីហូបនោះ ស្លាប់តាមផ្លូវតគ្នារដឹក មិនដឹងថាកប់នរណាទុកនរណាទេ ។

ដានីៈ ហើយដល់ពេលគាត់ស្លាប់បានប៉ុន្មានទៅ បានគាត់រៀបការជាមួយអ៊ី?

ទុំៈ គាត់ស្លាប់ បានប៉ុន្មានខែទេបានទៅរៀបនៅជំរំនោះ ។ មិនយូរទេ គ្រាន់តែស្លាប់យប់ហ្នឹង ទុកដាក់គាត់ហើយហ្នឹង ថៃគេដេញទៅទៀត អត់មានបានយូរណា៎ សឹងតែទុកគាត់មិនទាន់ ទុកហ្នឹង អត់ឲ្យថៃឃើញទៀត ទុកដីថៃ ។

ដានីៈ ហើយអត់មានពីណាទៅរក ផ្នូរគាត់អីវិញអត់ដែរទេ?

ទុំៈ អត់ទេ! ទៅរកម៉េចឃើញ ។ មិនដឹងជាវាលប៉ុណ្ណាអីប៉ុណ្ណាទៅរកមិនឃើញទេ សុទ្ធតែផ្នូរនៅតំរៀបគ្នា មានទៅកប់ជ្រៅណាកប់ប្រហែលៗឲ្យតែជិតៗហ្នឹង ឈើខ្ទាំងណា ។

ដានីៈ ហើយយ៉ាងម៉េចទៅ អ៊ីនៅជំរំបានរយៈពេលប៉ុន្មានទៅ បានចេញពីជំរំវិញ?

ទុំៈ ខ្ញុំនៅបានប៉ុន្មាន ប្រហែល ខ្ញុំទៅហ្នឹងរៀបហ្នឹងហើយ ដូចមិនយូរទេ ខ្ញុំមកវិញ ព្រោះអីនៅក្នុងជំរំ គេផ្អើរផ្លូងផាំងគេបាញ់ហើយនៅអត់បាន ក៏រត់មកវិញ រត់មកវិញមកនៅជាយព្រំដែនយើងវិញ ដល់មកនៅតាមជាយព្រំដែន មានអីចេះតែហូបហ្នឹងគេទៅ បើពីមុនអត់សូវកំសត់មកកំសត់អា៧៩ហ្នឹងយើងរត់ទៅមកហ្នឹងអត់អីហូបហើយស្លាប់ ។ ខ្ញុំថាមិនតែរស់ផង តែឈឺចូលដល់ជំរំហ្នឹងឯង បារាំងព្យាបាល បារាំងព្យាបាលបានជាហ្នឹង កុំអីងាប់បាត់តាំងពីនោះមកគ្មានបានរស់ទេ ។

ដានីៈ នៅតាមជាយដែនហ្នឹងទៅ?

ទុំៈ ចា៎ស!

ដានីៈ ដល់ឆ្នាំណាបានមកនៅនេះ?

ទុំៈ មកពីឆ្នាំ៧០ប៉ុន្មាន ព្រោះ៧៩យើងរត់ ។ ឆ្នាំ៨០យើងមកវិញ យើងមកវិញ រត់មួយសារទៀត រត់មួយសារទៀតកូនខ្ញុំអានេះវាទើបចេះដើរតិះតាក់ រត់មួយសារទៀត គេរត់ចោលអស់ទៅជំរំទាំងតាផុក ។ ទៅជំរំតាផុកហ្នឹង អត់បាយអត់ទឹកទេ ស្ពាយកូន កូនមានពីរ នៅអង្គុយនោះមួយ ហីហ្នឹងមួយ ។

ដានីៈ ចុះអ៊ីប្រុស កាលហ្នឹងគាត់ធ្វើអីដែរ?

ទុំៈ គាត់នៅជាមួយហ្នឹង ប៉ុនគាត់រត់ទៅមុន គាត់រត់ទៅមុនទៅរែកឆ្នាំងរែកចាន រែកអង្ករទៅ គាត់ក៏ទៅមុនបែកគ្នា បែកគ្នាដល់ទៅរកឃើញ ឃើញនៅដឹងវាលខាងណាទេ ដីថៃនោះ ។

ដានីៈ គាត់ពិការភ្នែកមួយចំហៀង?

ទុំៈ ចាស! ពិការភ្នែក ។

ដានីៈ ពិការតាំងពីអង្គាល?

ទុំៈ ហ្នឹង ខ្ញុំអត់ដឹងទេ អត់ដឹងគាត់ពិការតាំងពីឆ្នាំប៉ុន្មាន សួរប្អូនគាត់បានដឹងព្រោះអី គាត់នៅធ្វើសង្គ្រាម មិនដឹងជានៅឯណាខ្លះ អត់ស្គាល់ ។

ដានីៈ ចុះដល់ពេលសមាហរណកម្មហើយបាននៅនេះ ឬក៏នៅនេះតាំងពីមុនសមាហរណកម្ម?

ទុំៈ នៅនេះ ។

ដានីៈ ឆ្នាំណា?

ទុំៈ យើងផ្តាច់ខ្លួនហើយ ។

ដានីៈ ផ្តាច់ខ្លួនហើយ បាននៅនេះ?

ទុំៈ ផ្តាច់ខ្លួនហើយ បាននៅហ្នឹង ដល់ពេលផ្តាច់ខ្លួនមិនឃើញដើរទៅមកៗតាមហ្នឹង ចេះតែឆ្ងល់ហ្នឹង គេទៀតកាលហ្នឹង គេថាផ្តាច់ខ្លួនហើយម៉េចបានមានទាហានដើរ ។

ដានីៈ ហើយដល់ពេលក្រោយមកគាត់ធ្វើប៉ូលីស?

ទុំៈ ណាគេ?

ដានីៈ អ៊ំប្រុស ។

ទុំៈ ឪហ្នឹង?

ដានីៈ បាទ!

ទុំៈ ឪហ្នឹង គាត់នៅទាហានរបស់គាត់ គាត់អត់ដើរទៅណាទេ គាត់ពិការនោះ ទាហានពិការនៅចាំគេឲ្យប្រាក់ខែគាត់ហូប គាត់ចេះតែនៅ ។

ដានីៈ គាត់សក្តិប៉ុន្មាន?

ទុំៈ សក្ត័១ចឹងហើយ គេហៅនាយសំណង់គេ ។

អ្នកជិតខាងៈ គាត់សក្ត័៣,សក្ត័២ ទាហានគាត់ហ្នឹង?

ទុំៈ ទាហានគាត់ហ្នឹង មិនដឹងម៉េច ។

អ្នកជិតខាងៈ ចុះម៉េចបានដឹងសក្ត័គាត់ប៉ុន្មាន?

ទុំៈ សក្ត័ឥឡូវនេះ?

អ្នកជិតខាងៈ កាលពីមុនសក្ត៣ ដល់ពេលនេះគេជិរុះ ។

ទុំៈ គេទម្លាក់ចោល គេទើបមកយកឥឡូវទៀតហ្នឹង ។ សក្ត១ សក្ត២ ពីមុនគេទម្លាក់ចោលមួយសារហើយហ្នឹង ហើយគេទើបឲ្យឡើងធ្វើទាហានវិញ ឡើងស៊ីប្រាក់ខែ គាត់ពិការ ។

ដានីៈ គាត់ពិការ?

ទុំៈ គេយកទៅដាក់ពិការ ឲ្យនៅហូបប្រាក់ខែ ។

អ្នកជិតខាងៈ កាលពីមុនសក្ត២ ជិរុះមកនៅសក្ត១ ។

ទុំៈ ប៉ុន្តែប្រាក់ខែមិនបានហូប គ្រាន់តែធ្វើអេស៊ីលីដាហ្នឹងហើយមិនទាន់បានបើកលុយទេ គាត់ស្លាប់ទៅ មិនទាន់បានបើកណា ឥឡូវបាន២ខែ គេមិនឲ្យឯណា អត់ដដែរហ្នឹង ។

ដានីៈ បាទ! ចឹងអ៊ឹអគុណច្រើនចំណាយពេលសំណេះសំណាលជាមួយខ្ញុំ ។

«ចប់»